# ស្ថានទូតសហរដ្ឋអាមេរិក ភ្នំពេញ, កម្ពុជា



Share 1

បកប្រែ: English

## ទីភ្នាក់ងារផ្តល់ជំនួយរបស់សហរដ្ឋអាមេរិក និងទីភ្នាក់ងារផ្តល់ជំនួយរបស់កូរ៉េ ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា ដើម្បីជួយប្រព័ន្ធអប់រំនៅកម្ពុជា

ចេញថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤



USAID និង KOICA បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា ដើម្បីផ្តល់ការបណ្តុះបណ្តាលផ្នែកព័ត៌មាននិងបច្ចេកទេសសារគមនាគមន៍ ដល់សិស្សសាលានៅកម្ពុជា ។

នៅថ្ងៃទី ១២ ខែសីហា ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់កូរ៉េ (KOICA) បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានៅស្ថានទូតអាមេរិក ដើម្បីផ្តល់ការបណ្តុះបណ្តាលផ្នែកព័ត៌មាននិងបច្ចេកទេសសារគមនាគមន៍ (Information and Communication Technology ឬ ICT) ដល់សិស្សសាលានៅកម្ពុជា ក្នុងន័យគាំទ្រផែនការជាយុទ្ធសាស្រ្តក្នុងវិស័យអប់រំរបស់ព្រះរាជាណាចក្រកម្ពុជា។

កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតអោយអ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ KOICA ចុះទៅធ្វើការនៅតាមទីតាំងអប់រំដែលជួយដោយទីភ្នាក់ងារ USAID នៅខេត្តសៀមរាប ក្រចេះ និងកំពង់ចាម។ អ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ KOICA ដែលមានបទពិសោធន៍ផ្នែក ICT នឹងបង្រៀនជំនាញកុំព្យូទ័រដល់សិស្សសាលានៅក្នុងបន្ទប់កុំព្យូទ័រដែលជួយដោយទីភ្នាក់ងារ USAID ។



កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតអោយអ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ KOICA ចុះទៅធ្វើការនៅតាមទីតាំងអប់រំដែលជួយដោយទីភ្នាក់ងារ USAID នៅខេត្តសៀមរាប ក្រចេះ និងកំពង់ចាម។

លោកស្រី Rebecca Black ប្រធានទីភ្នាក់ងារ USAID ប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា “នៅកម្ពុជាមានមនុស្សច្រើនដែលស្ថិតក្នុងវ័យក្មេង ដោយប្រហែលពាក់កណ្តាលនៃប្រជាជនស្ថិតក្នុងអាយុក្រោម ២៥ ឆ្នាំ។ ដោយមានប្រជាជនច្រើនស្ថិតនៅក្នុងវ័យក្មេងដូច្នេះ អ្នកផ្តល់ជំនួយអន្តរជាតិគួរតែផ្តោតការវិនិយោគទៅលើវិស័យអប់រំ។

កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតអោយទីភ្នាក់ងារ USAID និងទីភ្នាក់ងារ KOICA ធ្វើការជាមួយគ្នាដើម្បីផ្តល់ការបណ្តុះបណ្តាលដ៏មានសារៈសំខាន់ ដល់សិស្សសាលានៅក្នុងខេត្តទាំងបី”។ កិច្ចព្រមព្រៀងនេះផ្តល់ក្របខ័ណ្ឌមួយសំរាប់អោយទីភ្នាក់ងារទាំងពីរបន្តស្វែងយល់ពីឱកាសសំរាប់ធ្វើសហប្រតិបត្តិការថែមទៀត ដើម្បីពង្រីកលទ្ធភាពក្នុងការទទួលបានការសិក្សាប្រកបដោយគុណភាព ស្របតាមគោលដៅនិងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងផែនការជាយុទ្ធសាស្ត្ររបស់ខ្លួនក្នុងវិស័យអប់រំពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨។

ទីភ្នាក់ងារ USAID ប្រចាំនៅកម្ពុជាមានកម្មវិធីមួយចំនួនដែលគាំទ្រដល់កំណើនគុណភាព លទ្ធភាពទទួលបាន និងប្រយោជន៍ទាក់ទងនៃការអប់រំជាមូលដ្ឋានសំរាប់យុវជនកម្ពុជា ដូចជាតាមរយៈការផ្តល់អាហារូបករណ៍សំរាប់យុវជនដែលស្ថិតក្នុងស្ថានភាពខ្សត់ខ្សោយ អំណោយថវិកាសំរាប់កែលំអសាលារៀន ការរៀបចំ និងការធ្វើតេស្តទៅលើកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ បុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល។

ទីភ្នាក់ងារ USAID ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៦១ ដោយលោកប្រធានាធិបតីអាមេរិក John F. Kennedy ហើយដើរតួនាទីជាទីភ្នាក់ងារនាំមុខគេក្នុងការផ្តល់ជំនួយបរទេសរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ តាំងពីឆ្នាំ ១៩៩២ មក ទីភ្នាក់ងារ USAID បានចំណាយថវិកាប្រហែល ១ ពាន់លានដុល្លាអាមេរិកសំរាប់ការអភិវឌ្ឍន៍នៅកម្ពុជា៕

គេហទំព័រនេះគ្រប់គ្រងដោយក្រសួងការបរទេសសហរដ្ឋអាមេរិក។ ទស្សនៈឬគោលនយោបាយស្តីពីភាពជាឯកជន របស់អត្ថបទឬគេហទំព័រភ្ជាប់ ដែលនៅក្រៅគេហទំព័ររបស់យើង មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអាមេរិកទេ។